ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីប្រកាសព័ត៌មាន

## ស្តីពីករណីគ្រោះថ្នាក់ក្នុងសិប្បកម្មផលិតឥដ្ឋ លាង ស្រ៊ុន នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងនូវក្តីរន្ធត់ និងអាណិតអាសូរចំពោះកុមារី **ឆេង ស្រីភ័ក្រ** អាយុ១០ឆ្នាំ ជាកូនកម្មករឡឥដ្ឋ ដែលបានជួបគ្រោះថ្នាក់នៅសិប្បកម្មផលិតឥដ្ឋរបស់ម្ចាស់ឈ្មោះ **លាង ស្រ៊ុន** ស្ថិតនៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃសៅរ៍ ៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩ កន្លងទៅនេះ។ ក្រោយពីទទួលបានព័ត៌មាននេះ ក្រសួងបានចាត់ក្រុមអធិការកិច្ចការងាររបស់ក្រសួង មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម និងមន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ចុះធ្វើការអង្កេត និងបានចាត់វិធានការចំពោះសិប្បកម្មផលិតឥដ្ឋនេះ ដូចខាងក្រោម៖

១-ផាកពិន័យសិប្បកម្មផលិតឥដ្ឋនេះ ស្របតាមមាត្រា៣៦៨ (ការងារសំរាប់ក្មេង) នៃច្បាប់ស្តីពីការងារ

២-កសាងសំណុំរឿងបណ្តឹងព្រហ្មទណ្ឌលើម្ចាស់សិប្បកម្មផលិតឥដ្ឋខាងលើ អំពីករណីប្រើប្រាស់ពលកម្មកុមារ និងខ្វះវិធានការការពារសុវត្ថិភាពកុមារមិនឱ្យចូលកៀកទៅកន្លែងខ្សែសង្វាក់ផលិតកម្ម។

ដោយឡែក កុមារីរងគ្រោះទទួលបានការគាំទ្រពីរបបសន្តិសុខសង្គមនៃក្រសួង ដូចខាងក្រោម៖

១-ការព្យាបាលរបួសរហូតដល់ជាសះស្បើយដោយមិនបង់ប្រាក់

២-សេវាស្តារនីតិសម្បទាឡើងវិញ

៣-ប្រាក់ឧបត្ថម្ភសម្រាប់ការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍មួយជីវិត

៤-ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យាបាលរបួស។

អាស្រ័យដូចជម្រាបជូនខាងលើ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ឆ្លៀតឱកាសនេះ ក្រសួងសូមក្រើនរំលឹកដល់ម្ចាស់សិប្បកម្មផលិតឥដ្ឋ សហគ្រាស គ្រឹះស្ថានទាំងអស់ជ្រាបថា ការប្រើប្រាស់ពលកម្មកុមារ គឺត្រូវអនុលោមឱ្យបានត្រឹមត្រូវតាមប្រកាសលេខ៣០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ។ ការប្រើប្រាស់កុមារក្រោមអាយុ១២ឆ្នាំ គឺជាបទល្មើសព្រហ្មទណ្ឌ។ ទន្ទឹមនឹងនេះ ការប្រើប្រាស់ពលកម្មកុមារអាយុក្រោម១៨ឆ្នាំ នៅតាមមណ្ឌលហាប់ នៅទីខ្ពស់ និងកន្លែងដែលមានប្រើប្រាស់សារធាតុគីមីត្រូវបានហាមឃាត់។ ក្រសួងនឹងចាត់វិធានការយ៉ាងតឹងរ៉ឹង ទាំងផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះសិប្បកម្មផលិតឥដ្ឋ សហគ្រាស គ្រឹះស្ថានទាំងឡាយដែលល្មើសនឹងករណីខាងលើនេះ។

ថ្ងៃចន្ទ ៦កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩